ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៤ សហវ.ពស

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពីការបង្វែរឥណទានជូនខេត្តប៉ៃលិន
# សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ២០៣ ប្រក សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង

- បានឃើញប្រកាសលេខ ១០៨៤ សហវ.ហម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិការាជធានី ខេត្ត ជូនខេត្តប៉ៃលិនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញសារាចរណែនាំលេខ ០០៨សហវ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៣
- យោងសំណើលេខ ១៥៥៥ ខបល. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាខេត្តប៉ៃលិន
- យោងសំណើលេខ ១៦៥៩ ខបល. ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់សាលាខេត្តប៉ៃលិន
- យោងលិខិតលេខ ១៧៨៦ លស ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់សាលាខេត្តប៉ៃលិនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការបង្វែរឥណទានដូចមានក្នុងតារាងខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៣ | ឥណទានកែប្រែ | | ឥណទានថ្មី |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| 61 | 615 | 6151 | ការថែទាំដីធ្លី សួនច្បារ និងរៀបជាផ្លូវ | 423.200 | 44.000 | | 467.200 |
| 62 | 622 | 6224 | សោហ៊ុយពិធីបុណ្យ | | | | |
| | | | *បុណ្យផ្សេងៗទៀត* | 15.000 | 10.000 | | 25.000 |
| 62 | 622 | 6226 | សោហ៊ុយសម្រាប់ការតាំងពិពណ៌នៅក្នុង និងក្រៅប្រទេស | 10.000 | | 10.000 | 0 |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 431.500 | 20.000 | | 451.500 |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 152.500 | | 20.000 | 132.500 |
| 64 | 645 | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 24.700 | 3.700 | | 28.400 |
| 64 | 645 | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 3.700 | | 3.700 | 0 |
| 65 | 652 | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | 76.000 | 39.700 | | 115.700 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 150.000 | | 150.000 | 0 |
| 21 | 214 | 2144 | បណ្តាញផ្លូវថ្នល់ និងស្ពាន | 2.747.000 | 66.300 | | 2.813.300 |
| | | | សរុប | 4.033.600 | 183.700 | 183.700 | 4.033.600 |

**ប្រការ២:** អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិនជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តប៉ៃលិន
- រតនាគារខេត្តប៉ៃលិន
  "ដើម្បីអនុវត្ត"
- ឯកសារ